អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១១

# សេចក្តីជូនដំណឹងដល់អ្នកសារព័ត៌មាន
# សវនាការរបស់អង្គជំនុំជម្រះសាលាដំបូង នៅថ្ងៃទី ៤ ខែឧសភា ឆ្នាំ២០១១

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងបើកសវនាការស្តីអំពីមាត្រា ៦៨(៣) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹង អៀង សារី។

សវនាការនឹងប្រព្រឹត្តទៅជាសាធារណៈនៅសាលសវនាការនៃ អ.វ.ត.ក ចាប់ពីម៉ោង ៩:០០ ព្រឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១១។

សាលសវនាការនៃ អ.វ.ត.ក មានកៅអីចំនួន៤៨២ សម្រាប់ទទួលអង្គទូត តំណាងសារព័ត៌មាន និងសាធារណជនទូទៅ។ គោលការណ៍នៃការបែងចែកកៅអីគឺ អ្នកមកមុនបានកន្លែងអង្គុយមុន។ តំណាងអង្គទូតនិងតំណាងសារព័ត៌មានដែលមានបំណងកក់កៅអីអង្គុយក្នុងសវនាការ សូមទាក់ទងមកផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក តាមរយៈសារអេឡិកត្រូនិក PAS@ECCC.GOV.KH យ៉ាងយឺតបំផុតត្រឹមម៉ោង ១៦:០០ រសៀល ថ្ងៃអង្គារ ទី៣ ខែឧសភា ឆ្នាំ២០១១។

អ្នកចូលរួមគួរតែមកដល់ អ.វ.ត.ក យ៉ាងតិច ៤៥នាទី មុនពេលបើកសវនាការ ដើម្បីទុកពេលវេលាគ្រប់គ្រាន់សម្រាប់ឲ្យខាងសន្តិសុខចុះឈ្មោះនិងឆែកឆេរ។ ដើម្បីអាចចូលទៅក្នុងបរិវេណសាលសវនាការបាន អ្នកចូលរួមត្រូវតែបង្ហាញអត្តសញ្ញាណប័ណ្ណ (មានបិទរូបថត) និងឆ្លងកាត់ការត្រួតពិនិត្យសន្តិសុខ។

អ្នកចូលរួមត្រូវតែប្រកាន់អាកប្បកិរិយាសមរម្យនិងថ្លៃថ្នូរគ្រប់ពេលវេលា និងមានសម្លៀកបំពាក់ត្រឹមត្រូវ (មិនអនុញ្ញាតឲ្យស្លៀកខោខ្លី សម្លៀកបំពាក់នៅមាត់សមុទ្រ ឬសម្លៀកបំពាក់ស្តើងហួសហេតុ ឬពាក់ស្បែកជើងផ្ទាត់ ។ល។)។ អ្នកចូលរួមមិនត្រូវស្លៀកសម្លៀកបំពាក់ដែលមានពាក្យស្លោកដែលបង្ហាញការគាំទ្រឬមាក់ងាយដល់ក្រុមណាមួយឡើយក្នុងអំឡុងសវនាការ។ សូមកត់សម្គាល់ថា អ្នកដែលមានអាយុក្រោម ១៦ឆ្នាំ នឹងមិនត្រូវបានអនុញ្ញាតឲ្យចូលក្នុងសាលសវនាការឡើយ ហើយអ្នកដែលមានអាយុចាប់ពី១៦-១៨ឆ្នាំ ត្រូវបានអនុញ្ញាតឲ្យចូលក្នុងសាលសវនាការតែក្នុងករណីមានមនុស្សចាស់មកជាមួយប៉ុណ្ណោះ។ មិនអនុញ្ញាតឲ្យយកទូរស័ព្ទដៃ កាបូបយួរឬស្ពាយ ចំណីអាហារ ឬភេសជ្ជៈចូលក្នុងសាលសវនាការឡើយ។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌដង្កោ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ២៣-២១៩-៨១៤ ទូរសារ (៨៥៥) ២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

**ការផ្ដល់ជូនតំណាងសារព័ត៌មាន**

នឹងមានការផ្ដល់ការផ្សាយបន្តផ្ទាល់អំពីដំណើរការសវនាការ នៅក្នុងបន្ទប់សម្រាប់អ្នកសារព័ត៌មាន (C-១០៥) ដែលស្ថិតនៅជាន់ផ្ទាល់ដីនៃសាលសវនាការ។ នៅក្នុងបន្ទប់ C-១០៨ មានកុំព្យូទ័រមួយចំនួនដែលភ្ជាប់ប្រព័ន្ធ អ៊ិនធឺណិត រួចជាស្រេច ដែលអ្នកសារព័ត៌មានអាចប្រើប្រាស់បាន។ អ្នកសារព័ត៌មានពុំត្រូវបានអនុញ្ញាតឲ្យភ្ជាប់កុំព្យូទ័រផ្ទាល់ខ្លួនទៅនឹងប្រព័ន្ធ អ៊ិនធឺណិត របស់ អ.វ.ត.ក ឡើយ។ ដូច្នេះ បើអ្នកសារព័ត៌មានណាម្នាក់មានបំណងភ្ជាប់ អ៊ិនធឺណិត ទៅនឹងកុំព្យូទ័រផ្ទាល់ខ្លួន សូមយក 3G modems ផ្ទាល់ខ្លួនមកជាមួយ។

តំណាងសារព័ត៌មានដែលមានបំណងចូលរួមតាមដានដំណើរការសវនាការនៅ អ.វ.ត.ក សូមយកមកជាមួយនូវប័ណ្ណព័ត៌មានដែលចេញដោយ អ.វ.ត.ក ឬចេញដោយស្ថាប័នរបស់ខ្លួន ដែលនៅមានសុពលភាពនៅឡើយ។

**តើធ្វើយ៉ាងណាដើម្បីទៅដល់ អ.វ.ត.ក ?**

អ.វ.ត.ក មានទីតាំងនៅខាងឆ្វេងដៃនៃផ្លូវជាតិលេខ៤ ក្នុងសង្កាត់ចោមចៅ ចម្ងាយ១៦គីឡូម៉ែត្រពី រាជធានីភ្នំពេញ។ តំណាងអ្នកសារព័ត៌មាននិងសាធារណជនសូមចូលតាមច្រកទ្វារសម្រាប់ភ្ញៀវដែលស្ថិត នៅទិសខាងកើត។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទចល័តៈ +៨៥៥ (0) ១២ ៤៨៨ ០២៣
ទូរស័ព្ទៈ +៨៥៥(0) ២៣ ៨១៤ លេខបន្តៈ ៦១៦៩
សារអេឡិកត្រូនិកៈ olsenl@un.org

**រាជ សម្បត្តិ**
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទដៃៈ +៨៥៥-១២ ៤៨៨ ១៥៦
ទូរស័ព្ទៈ +៨៥៥(0) ២៣ ៨១៤ លេខបន្តៈ ៦០៦៤
សារអេឡិចត្រូនិកៈ reach.sambath@eccc.gov.kh

**យូកូ ម៉ែដា**
មន្ត្រីកិច្ចការសាធារណៈ
ទូរស័ព្ទចល័តៈ +៨៥៥ (0) ១២ ៤៨៨ ៣១៩
ទូរស័ព្ទៈ +៨៥៥(0) ២៣ ៨១៤ លេខបន្តៈ ៦១៣៩
សារអេឡិកត្រូនិកៈ maeday@un.org

**ឌីម សុវណ្ណារុំ**
អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃៈ +៨៥៥-១២ ៤៨៨ ០៩៤
សារអេឡិចត្រូនិកៈ dim.sovannarom@eccc.gov.kh